# ខួបទី២៥ ឆ្នាំ នៃការប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

*ចុះផ្សាយថ្ងៃទី..... ខែកញ្ញា ឆ្នាំ២០១៨ - ម៉ោង៖ .... : ....*

**ភ្នំពេញ៖** ថ្ងៃច័ន្ទ ទី២៤ ខែកញ្ញា ឆ្នាំ២០១៨ នេះ គឺជាខួបទី២៥ឆ្នាំ ការប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សម័យរាជាណាចក្រទី២។ មកដល់បច្ចុប្បន្ននេះ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មានអាយុកាល២៥ឆ្នាំ និងត្រូវបានធ្វើវិសោធនកម្ម ៩ លើករួចមកហើយ។

ក្រោយកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ២៣ តុលា ១៩៩១ ដែលជាសមិទ្ធផលនៃការចរចារវាងឥស្សរជននយោបាយខ្មែរទាំងពីររូបគឺ សម្តេចនរោត្តមសីហនុ (ព្រះបរមរតនកោដ្ឋ) និងសម្តេច ហ៊ុន សែន (កាលនោះជាសមមិត្ត ហ៊ុន សែន) កម្ពុជាបានស្គាល់ការបោះឆ្នោតតាមបែបប្រជាធិបតេយ្យ សេរី ពហុបក្ស ជាលើកដំបូង ក្រោយសង្គ្រាមស៊ីវិលជាង៣ទសវត្សរ៍។ ការបោះឆ្នោតនីតិកាលទី១ បានប្រព្រឹត្តិទ្បើងចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៣។ ហើយសភាធម្មនុញ្ញមួយបានចាប់បដិសន្ធិទ្បើងនៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៩៣ ដើម្បីតាក់តែងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។ កិច្ចការដំបូងនៃសភាធម្មនុញ្ញនាពេលនោះ គឺការអនុម័តបង្កើត «គណៈកម្មាធិការអចិន្ត្រៃយ៍រៀបរៀងរដ្ឋធម្មនុញ្ញ» នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៣។

បន្ទាប់ពីតាក់តែងរួច រដ្ឋធម្មនុញ្ញថ្មីនេះ ត្រូវបានសភាធម្មនុញ្ញអនុម័ត នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ នាសម័យប្រជុំលើកទី២ និងត្រូវបានព្រះបាទ នរោត្តម សីហនុ អតីតព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ឡាយព្រះហស្តលេខា ប្រកាសឱ្យប្រើជាផ្លូវការ នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។

មកដល់បច្ចុប្បន្ននេះ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាកម្ពុជា ឆ្នាំ១៩៩៣ នេះ ត្រូវរដ្ឋសភាជាតិ ធ្វើវិសោធនកម្មចំនួន ៩ ដង មកហើយគឺ៖

| | |
|---|---|
| លើកទី១ ៖ នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៩៤ | នាសម័យប្រជុំរដ្ឋសភា ជាវិសាមញ្ញ នីតិកាលទី១ |
| លើកទី២ ៖ នៅថ្ងៃទី៤ ខែមីនា ឆ្នាំ១៩៩៩ | នាសម័យប្រជុំរដ្ឋសភា ជាវិសាមញ្ញ នីតិកាលទី២ |
| លើកទី៣ ៖ នៅថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០១ | នាសម័យប្រជុំរដ្ឋសភា លើកទី៦ នីតិកាលទី២ |
| លើកទី៤ ៖ នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០៤ | នាសម័យប្រជុំរដ្ឋសភា លើកទី១ នីតិកាលទី៣ |
| លើកទី៥ ៖ នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៥ | នាសម័យប្រជុំរដ្ឋសភា លើកទី២ នីតិកាលទី៣ |
| លើកទី៦ ៖ នៅថ្ងៃទី២ ខែមីនា ឆ្នាំ២០០៦ | នាសម័យប្រជុំរដ្ឋសភា លើកទី៤ នីតិកាលទី៣ |
| លើកទី៧ ៖ នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៨ | នាសម័យប្រជុំរដ្ឋសភា លើកទី៧ នីតិកាលទី៣ |
| លើកទី៨ ៖ នៅថ្ងៃទី១ ខែតុលា ឆ្នាំ២០១៤ | នាសម័យប្រជុំរដ្ឋសភា លើកទី៣ នីតិកាលទី៥ |
| លើកទី៩ ៖ នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៨ | នាសម័យប្រជុំរដ្ឋសភា ជាវិសាមញ្ញ នីតិកាលទី៥ |

**ដកស្រង់** ៖ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ច្បាប់ស្តីពីវិសោធនកម្មរដ្ឋធម្មនុញ្ញ (ទាំង៩លើក)

**ដោយ ៖ RAC Media**, Lim Sovannrith